ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦ អនក្រ.បក

សេចក្តីសម្រេច

ស្តីពីការបង្កើតគណៈកម្មការ

ដើម្បីកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី ៤

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងមាត្រា៧ និងមាត្រា៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី៤ ដែលមានសមាសភាពដូចខាងក្រោម ÷

១-	តំណាងគណបក្សប្រជាជនកម្ពុជា	មួយរូប
២-	តំណាងគណបក្សហ៊្វុនស៊ិនប៉ិច	មួយរូប
៣-	តំណាងគណបក្សសមរង្ស៊ី	មួយរូប
៤-	តំណាងក្រសួងមហាផ្ទៃ	ពីររូប
៥-	នាយកនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ	មួយរូប

www.pheakdeylaw.com

ប្រការ ២.-

គណៈកម្មការនេះដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយរូប ដែលជ្រើសតាំងក្នុងចំណោមសមាជិកគណៈកម្មការដោយការបោះឆ្នោតតាមមតិភាគច្រើនដាច់ខាតពីសមាជិកគណៈកម្មការនេះ។

ប្រការ ៣.-

គណៈកម្មការខាងលើនេះមានតួនាទី និងភារកិច្ចសិក្សាស្រាវជ្រាវ ធ្វើរបាយការណ៍ និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីការបន្ថែមអាសនៈ ឬការរក្សាទុកចំនួនអាសនៈនៅដដែល ដោយផ្អែកលើស្ថានភាពប្រជាពលរដ្ឋ ស្ថានភាពភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច។

ប្រការ ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com